២-ពង្រឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត លេខ ០៨-១៧១២/៩៨ គជប ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៨ ដោយការបន្ថែមមូលហេតុមានសាក្សី បញ្ជាក់ថា ប្រធានគណៈកម្មការឃុំ រៀបចំការបោះឆ្នោត ប៉ុចំពក់ បានអនុញ្ញាតឲ្យភ្នាក់ងារសង្កេតការណ៍ម្នាក់ ក្នុងមួយគណបក្ស បានចូលសង្កេតការរាប់សន្លឹកឆ្នោត ។

៣-សេចក្តីសម្រេចនេះធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៨ នាសម័យប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ
ហត្ថលេខា និងត្រា
**ចាន់ សុខ**

ជាកិច្ចស្របត្រឹមត្រូវតាមច្បាប់ដើម
លេខាកត់ត្រា
**ម៉េង គីមលី**

★★★

ភ្នំពេញ,ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៨

## សេចក្តីសម្រេច លេខ ០៦ កបធ/សសរ

## ក្រុមប្រឹក្សាធម្មនុញ្ញ

***

-បានឃើញថា : ពាក្យបណ្តឹងរបស់គណបក្សហ្វ៊ុនស៊ិនប៉ិច លេខ ១៦២/៩៨ ន.ត.ក. ចុះថ្ងៃទី១១ ខែ សីហា ឆ្នាំ ១៩៩៨ ជំទាស់នឹងសេចក្តីសម្រេចបដិសេធរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ០៨-១៦១១/៩៨ គជប ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៨ ដែលបានបដិសេធ ពាក្យបណ្តឹង លេខ ០៣៦/៩៨ នតក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៨ របស់គណបក្ស ហ្វ៊ុនស៊ិនប៉ិច ប្តឹងពីគណៈកម្មការ ឃុំ រៀបចំការបោះឆ្នោត ទូទាំងខេត្តស្វាយរៀង ថាមិនគោរពនីតិវិធី នៃការប្តឹងតវ៉ា និងថាគ្មានភាពប្រក្រតី នៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ជាបណ្តឹងគ្មានមូលដ្ឋានច្បាស់លាស់ ។

-បានឃើញថា : គណៈកម្មការឃុំរៀបចំការបោះឆ្នោត នៅក្នុងខេត្តស្វាយរៀង ពុំបានផ្តល់អាទិភាពឲ្យគណបក្សណាមួយឡើយ ក្នុងការសង្កេតការណ៍បោះឆ្នោត ក៏ដូចជាការរាប់សន្លឹកឆ្នោត ។

-បានឃើញថា : នៅថ្នាក់គណៈកម្មការឃុំរៀបចំការបោះឆ្នោត ពុំមានបណ្តឹងតវ៉ា ពីភ្នាក់ងារសង្កេតការណ៍របស់គណបក្សពិសេស ភ្នាក់ងារសង្កេតការរបស់គណបក្សហ្វ៊ុនស៊ិនប៉ិចទេ ។

-បានឃើញថា : ពាក្យបណ្តឹងនេះគ្មានភស្តុតាងគ្រប់គ្រាន់ ដើម្បីបើកសវនាការ តាមមាត្រា ១១៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គប្បីក្រុមប្រឹក្សាធម្មនុញ្ញ សម្រេចបដិសេធពុំទទួលពាក្យបណ្តឹងតវ៉ានេះ ។

-យល់ឃើញថា ៖ សេចក្ដីសំរេចលេខ ០៨-១៦១១/៩៨ គជប ចុះថ្ងៃទី១១ ខែ សីហា ឆ្នាំ ១៩៩៨ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានលក្ខណៈត្រឹមត្រូវ ។

**សំរេច**

១-បដិសេធពាក្យបណ្ដឹងជំទាស់របស់គណបក្សហ្វ៊ុនស៊ិនប៉ិច លេខ ១៦២/៩៨ នគក ចុះថ្ងៃ ទី១១ ខែ សីហា ឆ្នាំ ១៩៩៨ ទាក់ទងនឹងសេចក្ដីសំរេច បដិសេធ របស់គណៈកម្មាធិការជាតិរៀបចំការឆ្នោត លេខ ០៨ - ១៦១១/៩៨ គជប ចុះថ្ងៃ ទី១១ ខែ សីហា ឆ្នាំ ១៩៩៨ ដែលបដិសេធពាក្យបណ្ដឹងលេខ ០៣៦/៩៨ នគក ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៩៨ របស់គណបក្សហ្វ៊ុនស៊ិនប៉ិច ប្ដឹងពីគណៈកម្មការប៉ុស្ដិ៍រៀបចំការបោះឆ្នោត ទូទាំងខេត្តស្វាយរៀង មិនគោរពនីតិវិធី នៃការប្ដឹង តវ៉ា និងភាពមិនប្រក្រតី នៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។

២-តម្កល់សេចក្ដីសំរេចរបស់គណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត លេខ ០៨-១៦១១/៩៨ គជប ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៨ ដោយការប្ដូរមូលហេតុថា នៅក្នុងថ្នាក់ គណៈកម្មការប៉ុស្ដិ៍រៀបចំការបោះឆ្នោត ពុំមានបណ្ដឹងពីភ្នាក់ងាររបស់គណបក្ស ពិសេសភ្នាក់ងាររបស់គណបក្សហ្វ៊ុនស៊ិនប៉ិច ទេ ។

៣-សេចក្ដីសំរេចនេះធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៨ នាសម័យប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសំរេចស្ថាពរពុំមានផ្លូវតវ៉ា ។

| | |
|---|---|
| ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ | ថតចំលងត្រឹមត្រូវតាមច្បាប់ដើម |
| បានចុះហត្ថលេខា និងត្រា | លេខាធិការ |
| **ចាន់ សុខ** | **ម៉េង គឹមលី** |

★★★

ភ្នំពេញ,ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៨

## សេចក្ដីសំរេច លេខ ០៧ កបធ/សសរ

## ក្រុមប្រឹក្សាធម្មនុញ្ញ

***

-យល់ឃើញថា ៖ ពាក្យបណ្ដឹង លេខ ១៦២/៩៨ ន.គ.ក. របស់គណបក្សហ្វ៊ុនស៊ិនប៉ិច ចុះថ្ងៃទី១១ ខែ សីហា ឆ្នាំ ១៩៩៨ ជំទាស់នឹងសេចក្ដីសំរេចនៃគណៈកម្មាធិការជាតិរៀបចំ ការបោះឆ្នោត លេខ០៨-១៦១៤/៩៨ គជប ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៨ ដែលបដិសេធពាក្យបណ្ដឹងគ្មានលេខ ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ១៩៩៨ របស់លោក ពុត ចន្ថារិទ្ធ ស៊ុយ នូ និងអ្នកអង្គម្ចាស់ នរោត្តម ចានុរា , ស្ដីពីការបដិសេធមិនទទួលស្គាល់លទ្ធផលនៃការបោះឆ្នោត នៅមណ្ឌល ខេត្តស្វាយរៀង ជាបណ្ដឹងមិនត្រឹមត្រូវទេ ។